*ឯជំណើងថា យួនឡើងមកវះពោះនោះ ជាជំណើងក្មេងក្វាយ អស់រយៈពេល ពីរបីថ្ងៃ ប្រជាជនក៏បានត្រឡប់មកវិញ ហើយធ្វើការងារតាមការបញ្ជារបស់កម្មាភិបាល* ***ប៉ុល ពត*** *ដូចដើមវិញ ។ ចំពោះសេចក្តីទុក្ខនៃគ្រួសារនេះ ខ្ញុំមិនចាំបាច់រៀបរាប់ទេ ព្រោះប្រជាជនស្ទើរតែទាំងអស់ ក្រៅពីកម្មាភិបាល* ***ប៉ុល ពត*** *សុទ្ធតែជួបប្រទះដូចគ្នា ។*

## គ្រួសារសុខាក្រោយថ្ងៃរំដោះ

*ក្រោយថ្ងៃរំដោះ គ្រួសារនេះ បានត្រឡប់ទៅសាងគេហដ្ឋាននៅភូមិអ្នកតាត្បាល់វិញ និងចាប់ផ្តើមធ្វើកសិកម្ម និងនេសាទកម្មដូចគ្រួសារដទៃដែរ ប៉ុន្តែជីវភាពគ្រួសារមិនរីកចម្រើនទេ ។ ខ្ញុំចាំបានថាធ្លាប់បានបរិភោគបាយជាំលាយជាមួយនឹងពោតក្រហម ដែលលោកឪពុកយកស្ករទៅដូរនៅឯស្រុកកោះធំ ខេត្តកណ្តាល ។*

| | |
|---|---|
| រឿងរ៉ាវជីវិតមិនពិតប្រាកដ | មិនអាចកំណត់ដោយខ្លួនឯងបាន |
| គ្រប់គ្នាសុទ្ធតែចង់រុងរឿងថ្កាន | តែមិនអាចបានតាមប្រាថ្នាឡើយ ។ |
| ជួនលិចជួនឡើងតាមតែវាសនា | ដែលកម្មបានចាររួចស្រេចមកហើយ |
| ត្រូវតែទទួលគេចមិនរួចឡើយ | តែដល់ពេលហើយគ្មានអ្នកជួយបាន ។ |
| បើចង់កែប្រែខ្សែរឿងជីវិត | ត្រូវមានគំនិតកុំភ្លឹកភ្លេចប្រាណ |
| ត្រូវខំសូត្ររៀនសាងកម្មកល្យាណ | ប្រាកដជាបានអនាគតរុងរឿង ។ |


កុមារា សាន សុជា